រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០១

**សេចក្តីសំរេច លេខ ០៩ សសរ**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីវាយតំលៃលើផលប៉ះពាល់ ដល់សំណង់ផ្ទះសំបែង និងដីធ្លីរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមគន្លងខ្សែបណ្តាញ ពីភ្នំពេញទៅខេត្តតាកែវ រហូតដល់ព្រំប្រទល់ប្រទេសវៀតណាម**

---

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**ប្រការ១** : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យ និងវាយតំលៃលើផលប៉ះពាល់ ដល់សំណង់ផ្ទះសំបែង និងដីធ្លីរបស់ប្រជាពលរដ្ឋដែលរស់នៅតាមគន្លងខ្សែបណ្តាញ ពីភ្នំពេញទៅព្រំប្រទល់ប្រទេសវៀតណាម សំរាប់គំរោងសាងសង់ខ្សែបណ្តាញជាតិ បញ្ជូនអគ្គិសនីភាគខាងត្បូងកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អ៊ុត ឈន** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជាប្រធាន |
| ២-ឯកឧត្តមអភិបាល និងអភិបាលខេត្តរង ខេត្ត-ក្រុង ដែលពាក់ព័ន្ធនឹងគំរោង | | | សមាជិក |
| ៣-លោក | **ឌី នរិន្ទ** | អគ្គនាយករង អគ្គិសនីកម្ពុជា | សមាជិក |
| ៤-លោក | **សំខាន់ ឌី** | ប្រធាននាយកដ្ឋាន ក្រសួងបរិស្ថាន | សមាជិក |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៥-លោក | អ៊ី មុំរិទ្ធ | អនុប្រធាននាយកដ្ឋាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-លោក | នាយ ទាំងសួន | អនុប្រធាននាយកដ្ឋាន ឧស្សាហកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-លោក | ទិចសំរ ហម្សវណា | ប្រធានការិយាល័យអគ្គិសនីខេត្ត-ក្រុង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |

**ប្រការ២** : គណៈកម្មការអន្តរក្រសួង មានភារកិច្ចដូចតទៅ :

-ចុះត្រួតពិនិត្យ និងវាយតំលៃលើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង និងដីធ្លីរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមគន្លងខ្សែបណ្តាញ ពីភ្នំពេញទៅខេត្តតាកែវ និងពីខេត្តតាកែវទៅព្រំប្រទល់ប្រទេសវៀតណាម សំរាប់គំរោងសាងសង់ខ្សែបណ្តាញផ្គត់ផ្គង់បញ្ជូនអគ្គិសនីភាគខាងត្បូងកម្ពុជា។

-រៀបចំ និងកំណត់ការឧបត្ថម្ភ ចំពោះផលប៉ះពាល់លើសំណង់ផ្ទះសម្បែង និងដីធ្លីរបស់ប្រជាពលរដ្ឋ ដោយសារគំរោងខាងលើ ។

-ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលអនុវត្តបាន និងសុំយោបល់សំរេចពីរាជរដ្ឋាភិបាល ក្នុងករណីចាំបាច់ ។

**ប្រការ៣** : គណៈកម្មការអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសំរួលការងារ ។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសមាភាពដូចចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

www.pheakdeylaw.com